00145436

ឯកសារ/Nº : C3/12

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des Co-juges d'instruction

សំណុំរឿងព្រហ្មទណ្ឌ
Criminal Case File /Dossier pénal
លេខ/No: 002/14-08-2006

លេខស៊ើបសួរ/Investigation/Instruction
លេខ/No: 001/18-07-2007

# ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន
# Provisional detention Order
# Ordonnance de placement en détention provisoire

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៦៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ភេទ ប្រុស កើតថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ ភូមិពោរវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ សញ្ជាតិ ខ្មែរ របររកស៊ី គ្រូបង្រៀន ឪពុកឈ្មោះ **កាំង គី** (ស្លាប់) ម្តាយឈ្មោះ **មាស គីមសឿវ** (រស់) ប្រពន្ធឈ្មោះ **ឈឹម សុផល** (ស្លាប់) មានកូន ០៤ នាក់ ទីលំនៅបច្ចុប្បន្ននៅភូមិ អូរទន្ទឹម ឃុំ តាសាញ់ ស្រុក សំឡូត ខេត្តបាត់ដំបង

ត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៥, ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

00145437

ឯកសារ/N° : C3/11

បានឃើញការដដែកដេញដោលដែលបានធ្វើនៅថ្ងៃនេះ។

**សំអាងហេតុ:**

ដោយផ្អែកលើលទ្ធផលនៃការស៊ើបសួរដែលកំពុងដំណើរការ:

## I-សេចក្ដីថ្លែងនៃអង្គហេតុ និងអង្គច្បាប់

១- នៅក្នុងស្ថានភាព (ដោយមិនប៉ះពាល់ដល់លទ្ធផលនៃការស៊ើបសួរកំពុងដំណើរការ ដែលអាចនាំអោយកំណត់បទល្មើសផ្សេងទៀតដែលបានចង្អុលបង្ហាញនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងដែលអាចត្រូវដាក់ជាបន្ទុកចំពោះបុគ្គលពាក់ព័ន្ធនេះ) **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ត្រូវបានប្ដឹងចោទពីការបានគ្រប់គ្រងមជ្ឈមណ្ឌលសន្តិសុខ ស-២១ នៅចន្លោះ ឆ្នាំ ១៩៧៥ និង ១៩៧៩ ជាកន្លែងដែលការរំលោភបំពានឥតគណនាត្រូវបានប្រព្រឹត្តនៅក្រោមអំណាចរបស់ខ្លួនប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិល (ការឃុំឃាំងដោយបំពាន ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត ការសម្លាប់រង្គាល ។ល។) ដែលស្ថិតក្នុងក្របខ័ណ្ឌនៃការអនុវត្តនយោបាយជាលក្ខណៈប្រព័ន្ធ ឬមានលក្ខណៈទូទៅដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។
**កាំង ហ្គេកអ៊ាវ** ត្រូវបានដាក់បន្ទុកតាមរយៈភស្ដុតាងឯកសារ និងចម្លើយសាក្សីជាច្រើន។

**សហព្រះរាជអាជ្ញា**នៃអង្គជំនុំជម្រះវិសាមញ្ញស្នើអោយមានការឃុំខ្លួនបណ្ដោះអាសន្នដោយមូលហេតុថា៖

- មានហេតុផលពិតប្រាកដអោយជឿជាក់ថា **ឌុច** បានចូលរួមក្នុងឧក្រិដ្ឋកម្មដែលបានរៀបរាប់ក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ។
- ការឃុំខ្លួនបណ្ដោះអាសន្នគឺជាការចាំបាច់ដើម្បីបង្ការមិនអោយមានការគាបសង្កត់គ្រប់បែបយ៉ាងលើសាក្សីជាពិសេសអ្នកដែលធ្លាប់ស្ថិតនៅក្រោមអំណាចរបស់ជននេះ។
- មានភាពចាំបាច់ផងដែរក្នុងការធានាការរក្សាទុកជនត្រូវចោទសម្រាប់ដំណើរការយុត្តិធម៌ដោយពិចារណាដល់ស្ថានភាពដែលអាចមានការគេចខ្លួន និងដើម្បីការពារសុវត្ថិភាពផ្ទាល់របស់ជនពាក់ព័ន្ធនេះ។ និង
- ជាចុងក្រោយការរក្សាសណ្ដាប់ធ្នាប់សាធារណៈតម្រូវជាចាំបាច់។

**មេធាវី**ការពារជនត្រូវចោទលើកឡើងថា៖

- **ឌុច** ត្រូវបានជាប់ឃុំលើសពី ៨ឆ្នាំហើយ ដែលនេះជាការផ្ទុយនឹងច្បាប់ជាតិ និងបទដ្ឋានអន្តរជាតិ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ប្រអប់សំបុត្រលេខ ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

- អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចធានាអោយមានការគោរពបទដ្ឋានអន្តរជាតិផ្នែកយុត្តិធម៌ និងជាពិសេសមាត្រា ១៤ (៣-គ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងមាត្រា ៥-៣ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។
- លើសពីនេះការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងអង្គហេតុនេះមិនអាចធ្វើបានឡើយដោយហេតុលក្ខខណ្ឌនៃមាត្រា ៦៣ នៃវិធានផ្ទៃក្នុងមិនត្រូវបានបំពេញ ដោយហេតុថា **ឌុច** រស់នៅមានសេរីភាពតាំងពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩៩ ដោយមិនមានបង្កនូវភាពវឹកវរណាមួយឡើយ និងជាពិសេសក៏មិនមានការគាបសង្កត់ណាមួយកើតមានដែរ។
- **ឌុច** មិនមែនជាអ្នកដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យហើយមានមនុស្សជាងពីរពាន់នាក់ដែលធ្លាប់បានស្ថិតនៅក្នុងស្ថានភាពជាប្រធានមជ្ឈមណ្ឌលសន្តិសុខដូចរូបជនត្រូវចោទ។
- ជនសង្ស័យដទៃទៀតស្ថិតនៅក្នុងសេរីភាព និងជាផលវិបាកស្នើសុំអោយដោះលែងកូនក្តីរបស់ខ្លួនដោយស្នើអោយដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

**កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ប្រកាសថាគាត់ធ្លាប់ជាប្រធានមជ្ឈមណ្ឌល ស-២១ ហើយគាត់ត្រៀមខ្លួនដើម្បីធ្វើការបង្ហាញឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហម ហើយថាហេតុដូច្នេះមិនមានហេតុផលណាមួយអោយគិតថាគាត់អាចធ្វើការគាបសង្កត់លើសាក្សី ដែលលើសពីនេះគាត់មិនដឹងថានរណាជាសាក្សីនោះទេ។

២- នៅមុនការសម្រេចការឃុំខ្លួន **ឌុច** ជាបណ្តោះអាសន្ន យើងសូមធ្វើការរំលឹកស្ថានភាពពិសេសរបស់បុគ្គលនេះ ដែលមានលក្ខណៈលំបាកដោយឡែក ដែលសហចៅក្រមស៊ើបអង្កេតដែលមានកាតព្វកិច្ចធ្វើការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុកត្រូវសម្រេចចំពោះស្ថានភាពនេះ។ តាមពិតទៅ នៅពេលបច្ចុប្បន្ននេះ **ឌុច** ត្រូវបានចោទប្រកាន់នៅចំពោះមុខតុលាការយោធាភ្នំពេញ ដែលមានអង្គហេតុមួយផ្នែកមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ និងមានអង្គហេតុមួយផ្នែកផ្សេងទៀតដែលចូលក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ។ នៅក្នុងក្របខ័ណ្ឌនៃនីតិវិធីតុលាការយោធា **ឌុច** ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ហើយគាត់ត្រូវបានជាប់ឃុំតាំងពីពេលនោះមកនិងជាការប្រាកដណាស់ថា ការឃុំខ្លួននេះចោទជាបញ្ហាចំពោះការគោរពបទដ្ឋានអន្តរជាតិផ្នែកយុត្តិធម៌ និងដែលជាពិសេសចំពោះមាត្រា ៩(៣) និង ១៤ (៣-គ) នៃកតិកាសញ្ញាអន្តរជាតិទាក់ទងនឹងសិទ្ធិពលរដ្ឋ និងនយោបាយដែលផ្អែកតាមអត្ថន័យនៃមាត្រាទាំងនេះ គ្រប់បុគ្គលដែលត្រូវចាប់ខ្លួន ឬឃុំខ្លួនពីបទចោទនៃបទល្មើសព្រហ្មទណ្ឌត្រូវទទួលការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ឬត្រូវដោះលែងអោយមានសេរីភាព។

៣- កិច្ចព្រមព្រៀងចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាចែងយ៉ាងច្បាស់នៅក្នុងមាត្រា ១២ ថា អង្គជំនុំជម្រះវិសាមញ្ញបំពេញមុខងាររបស់ខ្លួនស្របតាមបទដ្ឋានអន្តរជាតិផ្នែកយុត្តិធម៌។ ដូច្នេះ គឺជាការចាំបាច់ក្នុងការពិនិត្យហេតុការណ៍ជាយថាហេតុនៃការឃុំខ្លួន **ឌុច** ដែលមានពីពេលមុន ដោយនៅពេលនេះ នីតិវិធីសម្រាប់

លេខ/ល៖ C3/9

**ឌុច** គឺជាកម្មវត្ថុនៅចំពោះមុខយើង។ ចំណោទអាចត្រូវលើកឡើងក្នុងន័យថា៖ ហេតុដែលជនត្រូវចោទបានស្ថិតនៅក្នុងការឃុំខ្លួនអស់រយៈពេលជាង ៨ ឆ្នាំ នៅក្នុងក្របខ័ណ្ឌនីតិវិធីដាច់ដោយឡែកអនុវត្តនៅចំពោះមុខយុត្តាធិការមួយផ្សេងទៀត តើមានលក្ខណៈប៉ះពាល់ដល់នីតិវិធីបច្ចុប្បន្នដែរឬទេ? ឬ លើសពីនេះទៀត ការឃុំខ្លួនបែបនេះមានលក្ខណៈហួសហេតុ និងបំពានដល់សិទ្ធិការពារខ្លួនដែលនឹងប៉ះពាល់ដល់ការប្តឹងមកយុត្តាធិការរបស់យើង (យុត្តាធិការដែលត្រូវបានបង្កើតនៅក្នុងអង្គការតុលាការកម្ពុជា ប៉ុន្តែជាស្ថាប័នឯករាជ្យដែលមានរចនាសម្ព័ន្ធដាច់ដោយឡែកពីយុត្តាធិការជាតិដទៃទៀត) និងនឹងមិនអនុញ្ញាតតទៅទៀតអោយមានការឃុំខ្លួនជាថ្មីចំពោះជនត្រូវចោទ ហើយអាចនឹងរហូតដល់តម្រូវអោយបញ្ចប់ការប្តឹងចោទប្រឆាំងនឹងជននេះ ឬយ៉ាងណា?

## II- ទ្រឹស្តីច្បាប់ និងយុត្តិសាស្ត្រ

៤- នៅពេលនេះ ជម្រើសដែលមានចំពោះសហចៅក្រមស៊ើបអង្កេត មានដូចតទៅ៖ នៅទីនេះ តើត្រូវអនុវត្តបុរាណភាសិត *Male captus, bene detentus* (តុលាការអាចមាន យុត្តាធិការលើជនជាប់ចោទដោយមិនគិតដល់របៀបដែលបុគ្គលនោះត្រូវបានបញ្ជូនមកយុត្តាធិការរបស់តុលាការ) ឬបញ្ច្រាសមកវិញ ត្រូវអនុវត្តតាមទ្រឹស្តីនៃការរំលោភបំពាននីតិវិធីឬយ៉ាងណា? ការរំលឹកអំពីអត្ថន័យនៃសញ្ញាណទាំងពីរនេះគឺជាការចាំបាច់ នៅមុនពេលធ្វើការសម្រេចបញ្ហានេះ ។

### ក- *Male captus, bene detentus*

៥- មានឧទាហរណ៍ជាច្រើនណាស់ ទាំងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិនៅក្នុងការអនុវត្តសុភាសិតនេះ ដែលតាមន័យនៃសុភាសិត ស្ថានភាពដែលជនជាប់ចោទត្រូវបានបញ្ជូនមកចំពោះមុខតុលាការមិនមានផលអ្វីបន្តិចឡើយលើការជំនុំជម្រះជនជាប់ចោទ។ ភាគច្រើននៃស្ថានភាពដែលកើតពីមុនៗ គឺច្រើនទាក់ទងនឹងលក្ខខណ្ឌនៃការចាប់ខ្លួនជនត្រូវចោទនៅដើមដំបូង មិនសូវមានទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួនដែលមាននៅពេលក្រោយនោះទេ ប៉ុន្តែក្នុងករណីទាំងពីរនេះ ការសំអាងហេតុផលគឺមានលក្ខណៈដូចគ្នា។ នៅពេលនេះ ការរំលឹកអំពីសេចក្តីសម្រេចសំខាន់ៗនៅក្នុងរឿងនេះ គឺជាការមួយដ៏មានប្រយោជន៍ ប៉ុន្តែយើងពុំមានបំណងបង្ហាញអោយបានល្អិតល្អន់នូវសេចក្តីសម្រេចទាំងអស់នោះទេ។

៦- ចាប់តាំងពីដើមសតវត្សទី ១៩ នៅប្រទេសអង់គ្លេស គោលការណ៍ *Male captus, bene detentus* ត្រូវបានទទួលស្គាល់ស្គាល់ក្នុងរឿងក្តី *Scott* ៖ ជនសញ្ជាតិអង់គ្លេសដែលត្រូវគេស្វែងរក ចំពោះការផ្តល់សក្ខីភាពក្លែងត្រូវបានចាប់ខ្លួននៅប្រទេសប៊ែលហ្ស៊ិក និងបញ្ជូនមកចក្រភពអង់គ្លេស។ ជាការឆ្លើយតបនឹងអញ្ញត្រកម្មអសមត្ថកិច្ចដែលលើកឡើងដោយ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ECCC * CO-INVESTIGATING JUDGES

ឯកសារលេខ: C3/8

មេធាវីការពារក្តី យុត្តាធិការអង់គ្លេសសម្រេចយ៉ាងដូច្នេះថា៖ "*បញ្ហាដែលចោទឡើងគឺជាបញ្ហាដែលត្រូវស្វែងយល់ថាតើជាករណីយកិច្ចតុលាការ (....) ក្នុងការគិតគូរដល់ស្ថានភាពដែលបុគ្គលត្រូវបានបញ្ជូនមកចំពោះមុខតុលាការ ឬយ៉ាងណា។ ខ្ញុំយល់ឃើញថាយើងមិនអាចធ្វើការអង្កេតលើស្ថានភាពទាំងនោះទេ* "[1]។ ដំណោះស្រាយដូចគ្នាមាននៅក្នុងរឿងក្តី *Elliott*[2] (ប៉ុន្តែមានភាពខុសគ្នាបន្តិច ដោយប្រធានតុលាការ លោក Lord Goddard បានបន្ថែមថា៖ " តុលាការ នឹងអាចពិចារណានៅក្នុងការវិនិច្ឆ័យរបស់ខ្លួនប្រសិនបើយល់ថាការចាប់ខ្លួនមានភាពមិនប្រក្រតី ឬ រំលោភបំពាន ")។ នៅពេលក្រោយមកទៀត យុត្តិសាស្ត្រអង់គ្លេសមានការវិវត្តដូចដែលមាននៅក្នុងការបកស្រាយនៅផ្នែកខាងក្រោមចំពោះរឿងរំលោភនីតិវិធី។

៧- តុលាការកំពូលសហរដ្ឋអាមេរិកតែងតែអនុលោមតាមគោលការណ៍ *Male captus, bene detentus* ។ នៅក្នុងរឿងក្តី *Ker. ប្រឆាំងនឹង Illinois* ជនជាប់ចោទជាពលរដ្ឋអាមេរិកដែលត្រូវបាននាំខ្លួនដោយបង្ខំពីប្រទេសប៉េរូមកសហរដ្ឋអាមេរិកបន្ទាប់ពីមានអំពើចាប់ពង្រត់ បានជំទាស់សមត្ថកិច្ចរបស់យុត្តាធិការអាមេរិក។ តុលាការបានធ្វើការឆ្លើយតបថា៖ " *ការចាប់ពង្រត់ដោយបង្ខំបែបនេះ មិនមែនជាហេតុផលគ្រប់គ្រាន់សម្រាប់ជនជាប់ចោទមិនទទួលខុសត្រូវចំពោះបទល្មើសដែលជនជាប់ចោទត្រូវបានចោទប្រកាន់ឡើយ នៅពេលដែលជនជាប់ចោទត្រូវបានដាក់អោយជំនុំជម្រះចំពោះមុខតុលាការដែលមានសិទ្ធិវិនិច្ឆ័យសេចក្តីចំពោះបទល្មើសបែបនេះ ហើយការចាប់ពង្រត់នេះមិនមែនជាឧបសគ្គដែលមានអានុភាពនាំអោយតុលាការមិនអាចជំនុំជម្រះជនជាប់ចោទនេះឡើយ* "[3] ។ នៅក្នុងឆ្នាំ ១៩៥២ សេចក្តីសម្រេចរឿងក្តី *Frisbie* ប្រឆាំងនឹង *Collins*[4] មានសំអាងហេតុប្រហែលគ្នាផងដែរ។ ក្រោយមកទៀត បញ្ហានេះបានក្លាយជាប្រធានបទពិភាក្សាយ៉ាងខ្លាំងក្លានៅអាមេរិក៖ ដូចដែលមានរៀបរាប់ខាងក្រោម (*CF B, No. 13* ) ក្នុងឆ្នាំ ១៩៧៤ សាលាឧទ្ធរណ៍សហព័ន្ធបានបដិសេធការអនុវត្តវិធានរឿងក្តី *Ker - Frisbie* នៅក្នុងរឿងក្តី *Toscanino.*[5] ។ ប៉ុន្តែ តុលាការកំពូលបានរក្សាជំហរដដែលរបស់ខ្លួនចំពោះរឿងក្តី *Alvarez- Machain*[6] (ប៉ុន្តែ មានការបញ្ជាក់ដែរថាសេចក្តីសម្រេចនេះត្រូវបានចៅក្រមដែលមានយោបល់ជំទាស់ចាត់ទុកថាជា "សេចក្តីសម្រេចដ៏ចម្លែកមួយ"........ )។

---

[1] Ex parte Susanna Scott (1829) 9 B. & C. 446, 109 E.R. 106

[2] R.v O/C Depot Batallion, RASC Colchester (Ex parte Elliott) (1949), 1 All E.R. 373 KB, p. 376 et 377.

[3] *Ker v. Illinois (1986) 119, U.S. 436*

[4] *Frisbie v. Collins (1952), 342 U.S. 519*

[5] *US v. Toscanino (1974) 500 F 2d 267*

[6] *US v. Alvarez-Machain (1992) 504 US 655*

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

00145441

ឯកសារៈ C3/7

៨-នៅក្នុងសេចក្តីសម្រេច *Adolf EICHMANN* ចុះថ្ងៃទី១១-១២ ខែធ្នូ ឆ្នាំ១៩៦១ តុលាការដំបូងរបស់យេរុស្សាលិម (*Jerusalem*) បានប្រកាន់យកគោលជំហរដូចគ្នា ដោយសម្រេចថា ៖ “ នេះគឺជាវិធានច្បាប់គោលមួយ ដែលថាបុគ្គលម្នាក់កំពុងប្រឈមការជំនុំជម្រះពីបទល្មើសប្រឆាំងនឹងច្បាប់របស់រដ្ឋមួយ មិនអាចជំទាស់ការជំនុំជម្រះមកលើខ្លួនដោយលើកយកហេតុផលនៃភាពមិនស្របច្បាប់នៃការចាប់ខ្លួន ឬ ដោយលើកយកសំអាងមធ្យោបាយនៃការនាំខ្លួនជននោះមកកាន់ដែននៃយុត្តាធិការរបស់រដ្ឋបានឡើយ។ តុលាការនៅក្នុងប្រទេសអង់គ្លេស សហរដ្ឋអាមេរិក និង អ៊ីស្រាអែល បានចេញសេចក្តីសម្រេចជាបន្តបន្ទាប់ថា កាលៈទេសៈនៃការចាប់ខ្លួន និង មធ្យោបាយសម្រាប់ការនាំយកជនជាប់ចោទមកកាន់ទឹកដីនៃរដ្ឋមួយមិនមានការពាក់ព័ន្ធនឹងការជំនុំជម្រះលើជនជាប់ចោទឡើយ ហើយតុលាការខាងលើបានបដិសេធមិនពិនិត្យមើលកាលៈទេសៈទាំងនោះទេនៅក្នុងគ្រប់ករណីទាំងអស់ ។[7]”

៩- ដូចគ្នានេះដែរ តុលាការកំពូលប្រទេសបារាំង នៅក្នុងសាលដីកា *ARGOUD* ខែមិថុនា ឆ្នាំ១៩៦៤ បានសម្រេចថា៖ “*លក្ខខណ្ឌដែលជនត្រូវចោទ (....) ត្រូវបានចាប់ខ្លួន និងបញ្ជូនមកតុលាការ ដែលជាការប៉ះពាល់ដល់ច្បាប់ព្រហ្មទណ្ឌ ឬ គោលការណ៍ជាប្រពៃណីនៃច្បាប់យើង ដែលស្ថានភាពអាក្រក់នេះអាចនឹងលើកឡើងនោះ មិនមែនជាបញ្ហារហូតដល់អាចយកមកធ្វើជាមូលហេតុមោឃភាពនៃបណ្តឹងចោទប្រកាន់ឡើយ នៅពេលដែលការស្រាវជ្រាវ និង ការបង្ហាញការពិត មិនត្រូវបានរកឃើញថាមានវិការៈជាសារវ័ន្ត ឬ ការការពារក្តីមិនត្រូវបានគេផ្តល់លទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តសិទ្ធិរបស់ជនត្រូវចោទនៅចំពោះមុខយុត្តាធិការស៊ើបអង្កេត និង យុត្តាធិការជំនុំជម្រះ*”[8]។ នៅក្នុងសេចក្តីសម្រេច BARBIE នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៨៣ តុលាការកំពូលបានបញ្ជាក់ឡើងវិញនូវការវិភាគរបស់ខ្លួនដោយប្រើប្រាស់ពាក្យស្ទើរតែដូចគ្នាថា៖ “មិនមានឧបសគ្គណាមួយដល់ការអនុវត្តបណ្តឹងអាជ្ញាប្រឆាំងនឹងជនត្រូវចោទឡើយ (....) នៅពេលដែលសិទ្ធិការពារក្តីដ៏ពេញលេញត្រូវបានធានាដោយសេរីដល់ជនត្រូវចោទនៅចំពោះមុខយុត្តាធិការស៊ើបអង្កេត និងយុត្តាធិការជំនុំជម្រះ”[9]។

១០- តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉ូវ៉ាន់ដា (*Rwanda*) បានប្រកាសជាច្រើនលើកថាតុលាការនេះមិនទទួលខុសត្រូវ

---

[7] តុលាការដំបូងរបស់ *Jerusalem, Israel v. Adolf Eichmann, Aff 40/61, 11-12* ធ្នូ ឆ្នាំ ១៩៦១*,Session 115* ផល. 119, 41.

[8] Cass. Crim. 4 juin 1964, Bull. 192, JCP 1964, II, n. 13806 Rapport Comte

[9] Cass. Crim. 6 octobre 1983, Bull., JCP 1983, II, n. 20107 Rapport Le Gunehec, Concl. Dontenwille



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

លេខ/លិ : C3/6

ចំពោះភាពខុសច្បាប់នៃការចាប់ខ្លួន និងការឃុំខ្លួនជនជាប់ចោទឡើយ ប្រសិនបើករណីទាំងនេះមិនបានធ្វើឡើងតាមសំណើរបស់តុលាការនោះទេ។ នៅក្នុងសេចក្តីសម្រេច *Rwamakuba*[10] តុលាការបានបញ្ជាក់ថា តុលាការមិនមានសមត្ថកិច្ចជំនុំជម្រះលើលក្ខខណ្ឌនៃរយៈពេលឃុំខ្លួនរបស់ជនជាប់ចោទនៅមុនការតម្រូវការរបស់តុលាការឡើយ និងថាឧបាស្រ័យទាំងឡាយទាក់ទងទៅនឹងបញ្ហានេះត្រូវធ្វើនៅចំពោះយុត្តាធិការដែលបានសម្រេចអំពីការឃុំខ្លួននេះ។

១១- ដូចនេះ មានប្រពៃណីដ៏រឹងមាំដែលគាំទ្រដល់ការបែងចែកច្បាស់លាស់រវាងនីតិវិធីអនុវត្តដោយស្របច្បាប់នៅចំពោះមុខយុត្តាធិការមួយ និង ការចាប់ខ្លួន ឬ ការឃុំខ្លួនដែលបានសម្រេចពីមុនដែលមានភាពខុសច្បាប់ដោយអាជ្ញាធរផ្សេងទៀត។ ប៉ុន្តែ ប្រពៃណីបែបនេះមានដែនកំណត់របស់ខ្លួននៅក្នុងទ្រឹស្តីនៃការរំលោភបំពានតិវិធី។

**ខ- ការរំលោភបំពាននីតិវិធី**

១២- ទ្រឹស្តី "ការរំលោភបំពាននីតិវិធី " មានការវិវត្តជាបន្តបន្ទាប់នៅក្នុងប្រព័ន្ធកុម្មិនឡូ (Common Law)។ នៅក្នុងសេចក្តីសម្រេច *Barayagwiza,* តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា (Rwanda) បានផ្តល់នូវនិយមន័យដូចខាងក្រោម តុលាការអាចនឹងឈានដល់ការប្រកាសអំពីអសមត្ថកិច្ច នៅពេលដែល៖ " *ដោយមានការរំលោភបំពានធ្ងន់ធ្ងរ និងជាក់ស្តែងលើសិទ្ធិរបស់ជនជាប់ចោទ ការអនុវត្តសមត្ថកិច្ចលើករណីបែបនេះអាចបណ្តាលអោយមានព្យសនកម្មដល់សុច្ចរិតភាពរបស់តុលាការ " ការបន្តដំណើរការក្តីនៅក្នុងករណីនេះគឺ "ផ្ទុយទៅនឹងទស្សនៈ ដែលថាតុលាការមានយុត្តិធម៌"*[11]។

១៣- នៅក្នុងរឿងក្តី *Toscanino,* នៅក្នុងឆ្នាំ ១៩៧៤ សាលាឧទ្ធរណ៍ថ្នាក់ទី ២ របស់សហរដ្ឋអាមេរិកបានយកទ្រឹស្តីនេះមកអនុវត្ត។ ជនជាប់ចោទដែលជាពលរដ្ឋអ៊ីតាលីត្រូវបានចាប់ពង្រត់ពីអ៊ុរុហ្គាយ (Uruguay) ដោយអាជ្ញាធររបស់អ៊ុរុហ្គាយ (Uruguay) និងនាំខ្លួនមកដោយបង្ខំមកកាន់ប្រទេសប្រេស៊ីល ដែលនៅទីនោះជនជាប់ចោទត្រូវបានឃុំខ្លួន និងធ្វើទារុណកម្មប្រហែលជិតបីសប្តាហ៍ បន្ទាប់មកនាំមកកាន់សហរដ្ឋអាមេរិកដែលនៅទីនោះជនជាប់ចោទត្រូវបានចោទពីបទឧក្រិដ្ឋទាក់ទងនឹងគ្រឿងញៀន។ តុលាការបានសំអាងថា៖ " យើងយល់ឃើញថាការគោរពនីត្យានុកូលភាពបច្ចុប្បន្ននេះទាមទារអោយតុលាការត្រូវបដិសេធការអនុវត្តសមត្ថកិច្ចលើជនជាប់ចោទប្រសិនបើជននេះត្រូវបានចាប់ខ្លួន បន្ទាប់ពីការបំពានដ៏លើសលុបដែលមានការគិតទុកជាស្រេច និងគ្មានហេតុផលទៅលើសិទ្ធិមានចែងក្នុងរដ្ឋធម្មនុញ្ញពីសំណាក់អាជ្ញាធរ "[12]។ ចំពោះ

[10] *Rwamakuba,*តុលាការដំបូង II, 12 ធ្នូ 2000, ,សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវី ដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ៣១ ឧសភា ២០០០, n. ICTR-97-20-A, par. 79, or *Kajelijeli,* 8 mai 2000 N. ICTR 98-44-1, par. 35

[11] *Barayagwiza,* Ch. App., 03 nov. 99, n. TPIR-97-19 AR72



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ប្រអប់សំបុត្រលេខ ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

00145443

ឯកសារលេខ: C3/5

*តុលាការ សេចក្តីសម្រេចផ្សេងទៀតនៅក្នុងស្ថានភាពបែបនេះនាំអោយ "ធានាដល់ភាពឃោរឃៅ និង ភាពខុសច្បាប់របស់នគរបាល "។*

១៤- ក្នុងរឿងក្តី Harrley[13] នូវែលហ្សេឡង់ជាប្រទេសដំបូងក្នុងចំណោមប្រទេសដទៃទៀតដែលអនុវត្តគោលការណ៍ទាំងនេះ។ នៅក្នុងរឿងក្តីនេះ ដែលមានពាក់ព័ន្ធនឹងបញ្ហាបត្យាប័នដែលមានលក្ខណៈបំភ័ន្ត ចៅក្រម Woodhouse បានបញ្ជាក់ថា៖ "*បញ្ហានេះ មិនត្រូវស្ថិតនៅក្នុងន័យដែលថាមានភាពគ្រប់គ្រាន់សមរម្យដើម្បីនឹងគិតដល់ការសម្រេចគោលដៅណាមួយនាំអោយអាចប្រើប្រាស់គ្រប់មធ្យោបាយនោះទេ។ បញ្ហាដែលចោទក្នុងរឿងក្តីនេះ គឺជាមូលដ្ឋាននៃទស្សនៈទានទាំងមូលនៃសេរីភាពនៅក្នុងសង្គម[14] ។"*

១៥- សាលាឧទ្ធរណ៍នៅអាហ្វ្រិកខាងត្បូង ក្នុងរឿងក្តី Ebrahim[15] បានអះអាងយ៉ាងដូច្នេះថា៖ "*បុគ្គលត្រូវទទួលការពារប្រឆាំងនឹងការឃុំខ្លួនដោយខុសច្បាប់ ទទួលការការពារប្រឆាំងនឹងការចាប់ពង្រត់ ។ ព្រំដែននៃយុត្តាធិការដែនដី និងអធិបតេយ្យភាពនៃរដ្ឋត្រូវតែទទួលបានការគោរព។ ភាពយុត្តិធម៌នៃដំណើរការក្តីត្រូវតែទទួលការធានា និងការបំពានសិទ្ធិត្រូវតែបញ្ចៀសមិនអោយមាន ការធ្វើយ៉ាងដូច្នេះគឺដើម្បីការពារ និងលើកស្ទួយសេចក្តីថ្លៃថ្នូរ និងសុចរិតភាពនៃប្រព័ន្ធយុត្តាធិការ។ ហេតុនេះរដ្ឋត្រូវគោរពវិធានទាំងនេះ ហើយរដ្ឋត្រូវចូលកាន់មកតុលាការដោយភាពស្អាតស្អំ។"*

១៦- តុលាការកំពូលបានអនុវត្តគោលការណ៍ទាំងនេះដែរ ក្នុងរឿងក្តីប្រហែលគ្នា Bennett[16]។ ចៅក្រម Lord Bridge of Harwich សង្ខេបសេចក្តីសម្រេចដូចតទៅ៖ " *តាមគំនិតរបស់ខ្ញុំ ការទទួលស្គាល់ថាតុលាការអាចបិទភ្នែកចំពោះការមិនគោរពច្បាប់ដែលអនុវត្តនៅក្រៅព្រំដែនយុត្តាធិការរបស់ខ្លួន គឺជាការយល់ឃើញដ៏ចង្អៀតចង្អល់ និងមិនអាចទទួលយកបាន។ ដូច្នេះ សម្រាប់រូបខ្ញុំ ការបានដឹងអំពីភាពខុសច្បាប់ហើយ ហើយទទួលស្គាល់ថាមានតែសំណង ឬ ដំណោះស្រាយនៅក្នុងដំណើរការក្តីរដ្ឋប្បវេណីចេញពីបណ្តឹងរបស់ចុងចោទ ឬដំណើរការក្តីចំពោះវិន័យ ឬដំណើរការក្តីផ្នែកព្រហ្មទណ្ឌប្រឆាំងនឹងមន្ត្រីម្នាក់ៗនៃភ្នាក់ងារអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងចំណាត់ការខុសច្បាប់តែ*

---

[12] *US v. Toscanino (1974) 500 F 2d 267, p. 275*

[13] Reg.v. Hartly (1978 ) 2 N.z.L.R.199

[14] *Ibid. 216-217*

[15] State v.Ebrahim, 1991 (2) S.A. 553

[16] *Re v. Horseferry Rd Magistrates"s Court (Ex parte Bennett) 24 juin 1993, [1994] A.C. 42*



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

លេខរឿង: C3/4

*ប៉ុណ្ណោះដែលអាចធ្វើបាន គឺជាចម្លើយមិនសមរម្យឡើយ។ ដោយហេតុថាការចោទប្រកាន់មិនអាចប្រព្រឹត្តទៅកើតឡើយ ប្រសិនបើគ្មានការចាប់ពង្រត់ដោយខុសច្បាប់ទេនោះ ជាផលវិបាកដំណើរការនីតិវិធីទាំងមូលត្រូវទទួលរងការប៉ះពាល់ (.....)។ ការយល់ឃើញថា ក្នុងកាលៈទេសៈបែបនេះ តុលាការអាចបដិសេធមិនអនុវត្តយុត្តាធិការរបស់ខ្លួនដោយហេតុដំណើរការនីតិវិធីមានការរំលោភបំពានអាចកើតចេញមកពីការបកស្រាយពន្លាតទ្រឹស្តីនៃរំលោភបំពាននីតិវិធី ប៉ុន្តែនៅក្នុងគំនិតខ្ញុំការបដិសេធមិនអនុវត្តយុត្តាធិការនេះ គឺជាការចាំបាច់ និងត្រឹមត្រូវទាំងស្រុង ។*

**១៧-** តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉ូហ្វាន់ដា (Rwanda) បានអនុវត្តទ្រឹស្តីនេះដែរ ក្នុងរឿងក្តី Barayagwiza[17] ដោយអះអាងនៅក្នុងសេចក្តីសម្រេចយ៉ាងដូច្នេះថា៖ “*ទោះបីបើស្ថាប័នទាំងបីនៃតុលាការមានកំហុសរួមគ្នា ឬ កំហុសកើតចេញពីសកម្មភាពនៃភាគីទីបី ដូចជាប្រទេសកាម៉ារូនក៏ដោយ ទង្វើនេះធ្វើឲ្យប៉ះពាល់ដល់សុចរិតភាពនៃដំណើរការជម្រះក្តីដែលត្រូវដំណើរការបន្ត។ លើសពីនេះទៀត គឺជាភាពអយុត្តិធម៌ចំពោះជនជាប់ចោទក្នុងការប្រឈមមុខចំពោះការជម្រះក្តីលើបទចោទនៅពេលដែលមានការរំលោភសិទ្ធិគាត់យ៉ាងធ្ងន់ធ្ងរបំផុត។ ហេតុនេះ ផ្អែកតាមទ្រឹស្តីនៃការរំលោភបំពានលើដំណើរការនីតិវិធី គឺមិនមានភាពពាក់ព័ន្ធជាមួយអង្គភាពណាដែលទទួលខុសត្រូវចំពោះការរំលោភបំពានលើសិទ្ធិរបស់ចុងចោទឡើយ។ វាមានភាពចាំបាច់ក្នុងការកត់សំគាល់ថា ទ្រឹស្តីនៃការរំលោភបំពានអាចត្រូវលើកឡើងទៅតាមអំណាចឆន្ទានុសិទ្ធិ។ នៅក្នុងដំណើរការក្តី តុលាការអាចមិនបំពេញយុត្តាធិការរបស់ខ្លួននៅពេលដែលមានការរំលោភបំពានសិទ្ធិជនជាប់ចោទដ៏ធ្ងន់ធ្ងរ និងដ៏អាក្រក់បំផុតដែលនេះជាការធ្វើអោយប៉ះពាល់សុចរិតភាពរបស់តុលាការ។ បទឧក្រិដ្ឋដែលបានចោទប្រឆាំងនឹងចុងចោទគឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរណាស់។ ក៏ប៉ុន្តែក្នុងរឿងក្តីនេះ សិទ្ធិជាសារវន្តរបស់ជនជាប់ចោទត្រូវបានរំលោភបំពានម្តងហើយម្តងទៀត (.....) ដោយមានការរំលោភបំពានជាច្រើន យើងសង្កេតឃើញថាការប្រព្រឹត្តនេះមានសភាពអាក្រក់បំផុត យើងសម្រេចថាដំណោះស្រាយតែមួយគត់ដែលអាចធ្វើបាន គឺដោះលែងចុងចោទ និងលើកលែងបទចោទប្រឆាំងនឹងចុងចោទ[18] ។*”

**១៨-** ប៉ុន្តែ ទ្រឹស្តីរំលោភបំពាននីតិវិធី ត្រូវបានបដិសេធដោយដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវីក្នុងរឿងក្តី NICOLIC[19]។ នៅក្នុងសេចក្តីសម្រេចនេះ តុលាការបានយល់ឃើញថាទ្រឹស្តីនេះយកមកអនុវត្តបានតែនៅពេលដែលជន

---

[17] *ជនត្រូវចោទត្រូវបានឃុំខ្លួនចាប់ពី ថ្ងៃទី ២១កុម្ភៈ ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ១៩៩៧ តាមសំណើរបស់រដ្ឋអាជ្ញា ដោយគ្មានការបញ្ជូនទៅជម្រះ។*

[18] *Barayagwiza, Ch.App., 03 nov 99, n TPIR-97-19-AR72, par 73 a 76*

[19] Nikolic TPIY Chambre de premirere Instance II, 9 Octobre 2002, IT-94-2-PT

00145445

ឯកសារ: C3/3

ជាប់ចោទទទួលរងការប្រព្រឹត្តដ៏អាក្រក់ និងធ្ងន់ធ្ងរ ដោយបញ្ជាក់ថា ៖ *"ការសម្រេចបែបនេះអាស្រ័យទាំងស្រុងផងដែរទៅតាមអង្គហេតុនីមួយៗ ហើយមិនអាចយកមកអនុវត្តជាលក្ខណៈអរូបីនោះទេ។ ជាផលវិបាក ត្រូវតែមានការវាយតម្លៃកម្រិតហិង្សាដែលបានប្រព្រឹត្តចំពោះជនជាប់ចោទ ។ ផ្អែកតាមអង្គហេតុ អង្គជំនុំជម្រះកត់សំគាល់ថាអង្គហេតុដែលបានសន្មតទោះបីបើបង្កើតនូវក្តីកង្វល់ខ្លះក៏ដោយ មិនមែនជាការប្រព្រឹត្តចំពោះជនជាប់ចោទដោយអញ្ញត្រជនដែលមានលក្ខណៈជាជាការរំលោភបំពានធ្ងន់ធ្ងរទាល់តែសោះ។"*

១៩- ដំណោះស្រាយបែបនេះ ក៏ត្រូវបានទទួលយកដោយតុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងរឿងក្តី Lubanga[20] ផងដែរ។ តុលាការយល់ឃើញថា ការរំលោភបំពានសិទ្ធិជនជាប់ចោទ ក្នុងពេលចាប់ខ្លួន ឬពេលឃុំខ្លួនដែលមានពីមុន អាចយកមកពិចារណាបានតែក្នុងពីរករណីប៉ុណ្ណោះ ៖ បើតុលាការ និងអាជ្ញាធរផ្សេងបានប្រព្រឹត្តក្នុងរបៀបត្រូវរ៉ូវគ្នា ឬប្រសិនបើជនជាប់ចោទនេះ ជាជនរងគ្រោះពីអំពើទារុណកម្ម ឬអំពើធ្វើបាបអាក្រក់ធ្ងន់ធ្ងរ។

## III. ដំណោះស្រាយក្នុងករណីនេះ

**២០-** ផ្អែកតាមធាតុផ្សំទាំងអស់ដែលបានរៀបរាប់ខាងលើ សហចៅក្រមស៊ើបអង្កេតយល់ឃើញថាខ្លួនមិនមានសមត្ថកិច្ចក្នុងការវាយតម្លៃពីភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួនកន្លងមកដែលធ្វើលើ **ឌុច** នោះទេ។ ហេតុដែលថា អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតនៅក្នុងប្រព័ន្ធតុលាការកម្ពុជានោះ មិនអាចនាំឲ្យមានការលើកឡើងថា តុលាការពិសេសដែលមានលក្ខណៈអន្តរជាតិ និងតុលាការយោធា បានបំពេញការងារដោយរបៀបត្រូវរ៉ូវគ្នានោះទេ៖ អង្គជំនុំជម្រះវិសាមញ្ញ ទើបតែបានចាប់ផ្តើមដំណើរការពីថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៧ ប៉ុណ្ណោះ គឺជាកាលបរិច្ឆេទនៃការចូលជាធរមាននៃវិធានផ្ទៃក្នុង។ នៅមុនពេលមានការបើកការស៊ើបសួរបច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេត (ដែលជាអ្នកមានសមត្ថកិច្ចតែមួយគត់ក្នុងការធ្វើសេចក្តីសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន) មិនមានលទ្ធភាពណាមួយក្នុងការចូលធ្វើអន្តរាគមន៍នោះទេ។ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញកិច្ចការ សហចៅក្រមស៊ើបអង្កេតទទួលបានបណ្តឹងអំពីចំណោទបញ្ហានេះ និងដោយពិចារណាដល់ពេលវេលាចាំបាច់សម្រាប់ការស្វែងយល់ពីសំណុំរឿង ពេលវេលាដែលកន្លងទៅ (12ថ្ងៃ) ចន្លោះពេលនៃការប្រគល់ដីកាបញ្ជូនរឿងឲ្យប្រគល់ដីកានាំខ្លួនមិនអាចត្រូវបានចាត់ទុកថាជាពេលវេលាយូរហួសហេតុ និងអាចចាត់ទុកជាការមិនយកចិត្តទុកដាក់នោះទេ ។

[20] CPI, Ch.Ap.Proc.c.Lubanga, affaire CPI-01/04-01/06, 14 Dec 06, par.42 ss



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

00145446

C3/2

២១- ទ្រឹស្តីនៃការរំលោភបំពាននីតិវិធីមិនអាចអនុវត្តបានទេក្នុងករណីនេះ។ យុត្តាធិការដែលប្រើប្រាស់សញ្ញាណនេះមិនមែនមិនគិតដល់ទាល់តែសោះអំពីសមាមាត្ររវាងការរំលោភបំពានដែលត្រូវចោទប្រកាន់ និងដំណោះស្រាយដែលស្នើឡើងនោះទេ។ ជាការពិតណាស់ដែលថានៅក្នុងរឿងក្តីនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបញ្ចប់ការចោទប្រកាន់អាចកើតមានបានតែនៅក្នុងករណីប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនជាប់ចោទ ជាឧទាហរណ៍យ៉ាងហោចក្នុងកំរិតអប្បបរមាដូចអ្វីដែលបានកើតមានឡើងនៅក្នុងរឿងក្តី Toscanino។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតបានជ្រើសរើសយកដំណោះស្រាយដែលបានប្រកាន់យកនៅក្នុងរឿងក្តី Nikolic ឬ Lubanga ដែលតម្រូវថា៖ ដើម្បីអនុវត្តទ្រឹស្តីនៃការរំលោភបំពាននីតិវិធីត្រូវមានការបង្ហាញពីការរំលោភបំពានធ្ងន់ធ្ងរ និងពិតប្រាកដលើសិទ្ធិជនជាប់ចោទ។ ដូច្នេះ នៅពេលណាដែលមិនមានរឿងបែបនេះទាល់តែសោះ ឬក៏រឿងចោទប្រកាន់ថា **ឌុច** បានទទួលរងនូវអំពើធ្វើទារុណកម្ម ឬការធ្វើបាបអាក្រក់ធ្ងន់ធ្ងរនៅមុនពេលបញ្ជូនខ្លួនមកកាន់អង្គជំនុំជម្រះវិសាមញ្ញនោះទេ ការឃុំខ្លួនបន្តដែលមាននៅតុលាការយោធាបើប្រៀបធៀបជាមួយនឹងបទឧក្រិដ្ឋដែលដាក់បន្ទុកលើជននេះ មិនអាចត្រូវចាត់ទុកថាមានលក្ខណៈគ្រប់គ្រាន់ជាការបំពានធ្ងន់ធ្ងរនោះទេ។ នីតិវិធីបច្ចុប្បន្នដែលជនត្រូវចោទទទួលបានសិទ្ធិការពារខ្លួនដ៏ពេញលេញនោះ នីតិវិធីនេះអាចដំណើរការបន្តបាន គួរបញ្ជាក់ថាអាចមានជាការជួសជុលចំពោះព្យសនកម្មដែលទទួលរងដោយសារការឃុំខ្លួនពីមុន (តាមរយៈការបន្ថយទោស ឬតាមវិធីផ្សេងទៀតដែលត្រូវសម្រេចដោយអង្គជំនុំជម្រះ) នោះនឹងមិនចោទជាបញ្ហាទេនៅក្នុងដំណាក់ស៊ើបសួរ។

២២- ដូច្នេះ បញ្ហាតែមួយគត់ដែលត្រូវសម្រេចគឺ៖ តើការឃុំខ្លួន **ឌុច** បណ្តោះអាសន្ន ជាការចាំបាច់ដែរ ឬអត់នៅពេលនេះ នៅក្នុងក្របខ័ណ្ឌដំណើរការនីតិវិធីដែលត្រូវចាប់ផ្តើមធ្វើចំពោះ **ឌុច** នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ? ទាក់ទិននឹងចំណុចនេះ ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតមានដូចតទៅ៖ អង្គហេតុដែលត្រូវដាក់បន្ទុកចំពោះជនត្រូវចោទមានលក្ខណៈធ្ងន់ធ្ងរ បទឧក្រិដ្ឋដែលបានកើតឡើងរយៈពេល៣០ឆ្នាំមកហើយនៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់សាធារណៈ ហេតុដូច្នេះមិនមែនជាការហួសហេតុពេកទេដែលអះអាងថា នៅក្នុងបរិបទដ៏ផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជននេះអាចនឹងបង្កឲ្យមានការសំដែងនូវការមិនពេញចិត្តជាទូទៅដែលអាចបង្កឲ្យមានអំពើហិង្សា ឬអាចប៉ះពាល់ដល់សន្តិសុខផ្ទាល់របស់ជននេះ។ ក្រៅពីនេះ ទោសឧក្រិដ្ឋមួយជីវិតដែល **ឌុច** ត្រូវប្រឈមនាំឲ្យបារម្ភថាជននេះអាចស្វែងរកការគេចខ្លួនពីដំណើរការតុលាការ។ ចុងបញ្ចប់ ដោយសេចក្តីបារម្ភថាសាក្សី និងជនរងគ្រោះពីអំពើប្រព្រឹត្តដ៏ធ្ងន់ធ្ងរបំផុតដែលដាក់បន្ទុកលើជននេះមានអារម្មណ៍ភ័យខ្លាច និងបដិសេធចូលរួមក្នុងដំណើរការតុលាការប្រសិនបើពុំមានការដាក់ឃុំខ្លួនជនត្រូវចោទ។

00145447

ឯកសារ/Nº: C3/1

២៣- ជាផលវិបាក៖

- ដោយយល់ឃើញថាមានហេតុផលពិតប្រាកដអោយជឿជាក់ថា **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** បានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ។
- យល់ឃើញថាជាការចាំបាច់ផងដែរដើម្បីធានាការរក្សាទុកជនត្រូវចោទសម្រាប់ដំណើរការតុលាការ និងដើម្បីការពារសុវត្ថិភាពផ្ទាល់របស់ជននេះ។
- យល់ឃើញថាការរក្សាសណ្តាប់ធ្នាប់សាធារណៈជាការចាំបាច់ ។
- យល់ឃើញថាមិនមានវិធានការណ៍ត្រួតពិនិត្យតាមផ្លូវតុលាការណាមួយទោះជាមានលក្ខណៈតឹងរ៉ឹងបែបណាក៏ដោយ នឹងមានប្រសិទ្ធិភាពជាទីពេញចិត្តឆ្លើយតបនឹងស្ថានភាពតម្រូវទាំងអស់នេះទេ ។ និង
- យល់ឃើញថាការឃុំខ្លួននៅតែជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចគោលដៅទាំងនេះ។

**ផ្អែកតាមហេតុផលទាំងនេះ៖**

យើងបង្គាប់ឲ្យឃុំខ្លួន **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ជាបណ្តោះអាសន្ន រយៈពេលអតិបរមាមួយឆ្នាំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៧

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juges d'instruction

យូ ប៊ុនឡេង

MARCEL Lemonde

ដីកានេះធ្វើជាភាសាខ្មែរ និង ភាសាបារាំង និង បកប្រែជាភាសាអង់គ្លេស ។

យើង.........................................បានប្រគល់ដីកានេះដល់ឈ្មោះខាងក្រោមនៅថ្ងៃទី........ខែ........... ឆ្នាំ...........

ជនត្រូវចោទ មេធាវីជនត្រូវចោទ សហព្រះរាជអាជ្ញា ការិយាល័យរដ្ឋបាល ក្រឡាបញ្ជី

តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទត្រូវបានប្រាប់ថា៖

- ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ននេះ ស្របតាមលក្ខណ្ឌដែលមានចែងក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។
- ក្នុងពេលឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ ឬមេធាវីរបស់គេអាចធ្វើសំណើសុំដោះលែងទៅ សហចៅក្រមស៊ើបអង្កេតបានគ្រប់ពេលវេលា ។
- បើស្ថានភាពផ្លាស់ប្តូរក្រោយពេលដាក់ពាក្យសុំចុងក្រោយ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសារជាថ្មីម្តងទៀតក្នុងរយៈពេលមិនឲ្យតិចជាង ៩០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយលើពាក្យសុំដោះលែងនៅក្រៅឃុំពីពេលមុន។
- នៅគ្រប់ករណីទាំងអស់ ជនត្រូវចោទមានសិទ្ធិត្រូវបាននាំខ្លួនទៅជួបសហចៅក្រមស៊ើបអង្កេត យ៉ាងហោចណាស់រៀងរាល់ ១២០ ថ្ងៃម្តង ហើយត្រូវផ្តល់ឱកាសដើម្បីពិភាក្សាអំពីប្រព្រឹត្តិកម្ម និងលក្ខខណ្ឌនៃការឃុំខ្លួន ។
- នៅពេលជួបសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទអាចធ្វើការស្នើសុំផ្សេងៗ ហើយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីសំណើនេះ។
- ជនត្រូវចោទអាចធ្វើការកត់សម្គាល់មុនពេលដែលសហចៅក្រមស៊ើបអង្កេតសម្រេចអំពីការបន្តការឃុំខ្លួនជនត្រូវចោទនេះ។ ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ប្រអប់សំបុត្រលេខ ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.